# បណ្ឌរនាគរាជជាតក




*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធទេវទត្តដែលធ្វើមុសាវាទ ហើយចូលទៅកាន់ផែនដី ( ផែនដីស្រូប) បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **វិភិណ្ណាវាចំ** *ដូច្នេះជាដើម ។*

*ក្នុងគ្រានោះ កាលភិក្ខុទាំងឡាយពោលទោសទេវទត្ត ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ទេវទត្តបានធ្វើមុសាវាទ ហើយចូលទៅកាន់ផែនដីដូចគ្នាដែរ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ក្នុងកាលនោះ ពាណិណា ៥០០ ចុះទៅសមុទ្រដោយនាវា ក្នុងថ្ងៃទី ៧ ពេលដែលនាវាបិតនៅក្នុងទីដែលមើលមិនឃើញច្រាំង នាវានោះក៏បានបែកនៅលើខ្នងសមុទ្រ មនុស្សទាំងឡាយលើក*

លែងតែមួយប៉ុណ្ណោះ បានក្លាយជាចំណីត្រីនិងអណ្តើក បុរសម្នាក់នោះ ដោយកម្លាំងនៃខ្យល់ ក៏បានដល់កំពង់ឈ្មោះ **ករម្បិយបដ្តន:** ។ បុរសនោះឡើងពីសមុទ្រ ជាអ្នកអាក្រាតកាយ ត្រាច់ទៅកាន់កំពង់នោះ ដើម្បីរកអាហារ ។ មនុស្សទាំងឡាយឃើញបុរសនោះ នាំគ្នាសរសើរថា សមណ:នេះមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ដូច្នេះហើយ ក៏ធ្វើសក្ការ: ។ បុរសនោះ គិតថា យើងបានឧបាយចិញ្ចឹមជីវិតហើយ ដូច្នេះហើយ កាលមនុស្សទាំងឡាយឲ្យសំពត់ស្លៀកដណ្តប់ ទើបមិនប្រាថ្នា ។ មនុស្សទាំងឡាយយល់ថា សមណ:ដែលប្រាថ្នាតិចដ៏ខ្ពង់ខ្ពស់ជាងនេះ រមែងមិនមាន ដូច្នេះហើយទើបនាំគ្នាជ្រះថ្លាឲ្យក្រែលែងឡើង ហើយធ្វើអាស្រមដល់បុរសនោះ និងញ៉ាំងបុរសនោះឲ្យនៅក្នុងទីនោះឯង ។ បុរសនោះក៏មានឈ្មោះប្រាកដថា **ករម្បិយអចេល** ។ លាភសក្ការ:ដ៏ធំបានកើតឡើង ដល់ករម្បិយអចេល ដែលនៅក្នុងទីនោះ ។

មានស្តេចនាគ និងស្តេចគ្រុឌមួយ តែងមកបម្រើអចេលនោះ ។ បណ្តាជនទាំងនោះស្តេចនាគមានឈ្មោះថា **បណ្ឌរ:** (មានពណ៌ស) ។ ថ្ងៃមួយ ស្តេចគ្រុឌមកកាន់សម្នាក់អចេលនោះ ហើយអង្គុយក្នុងទីដ៏សមគួរ រួចពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ញាតិទាំងឡាយរបស់ខ្ញុំកាលចាប់នាគ រមែងវិនាស់អស់ច្រើន ពួកខ្ញុំមិនដឹងវិធីចាប់នាគទាំងឡាយសោះ បានឮថា នាគទាំងនោះមានហេតុអាថ៌កំបាំង លោកម្ចាស់អាចឬទេ ដើម្បីសួរហេតុនោះ ដោយធ្វើដូចជាមានសេចក្តីស្រឡាញ់ ។ អចេលនោះទទួលថា ល្អ ។ កាលសុបណ្ណរាជថ្វាយបង្គំហើយចៀសចេញទៅ ក្នុងកាលដែលនាគរាជមក ថ្វាយបង្គំ រួចអង្គុយហើយនោះ ក៏បានសួរនឹងនាគរាជថា ម្នាលនាគរាជ បានឮថា គ្រុឌទាំងឡាយកាលចាប់ពួកលោក រមែងវិនាសអស់ច្រើន កាលគ្រុឌចាប់ពួកលោក ពួកលោកធ្វើដូចម្តេច ទើបគ្រុឌមិនអាចនឹងចាប់បាន ? នាគរាជពោលថា បពិត្រលោកម្ចាស់ នេះជាអាថ៌កំបាំងរបស់ពួកខ្ញុំ កាលខ្ញុំប្រាប់អាថ៌កំបាំង

នេះ ក៏ដូចជានាំសេចក្តីស្លាប់មកឲ្យដល់ពួកញាតិ ។ អចេលពោលថា ម្នាលអាវុសោ លោកសម្គាល់យើងដូចម្តេច លោកគិតថា យើងនឹងប្រាប់អាថ៌កំបាំងនេះដល់អ្នកដទៃឬ យើងនឹងមិនប្រាប់អ្នកដទៃទេ យើងសួរ ព្រោះគ្រាន់តែចង់ដឹងប៉ុណ្ណោះ លោកជឿយើងហើយ ចូរផុតចាកភ័យ សូមប្រាប់មក ។ នាគរាជពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនប្រាប់ទេ ថាហើយថ្វាយបង្គំ រួចចៀសចេញទៅ ។ សូម្បីក្នុងថ្ងៃស្អែក អចេលនោះបានសួរទៀត សូម្បីនាគរាជក៏ប្រាប់ដដែល ។

ក្នុងទី ៣ នាគរាជមកហើយ អង្គុយក្នុងទីដ៏សមគួរមួយ អចេលពោលថា ម្នាលនាគរាជ ថ្ងៃនេះជាថ្ងៃទី ៣ ហើយណា កាលអាត្មាសួរហើយ ហេតុអ្វី ទើបអ្នកមិនប្រាប់ ? នាគរាជពោលថា បពិត្រលោកម្ចាស់ ព្រោះភ័យខ្លាចលោកម្ចាស់ប្រាប់ដល់អ្នកដទៃ ។ អចេលពោលថា យើងនឹងមិនប្រាប់ដល់អ្នកណាឡើយ លោកចូរមិនមានភ័យ ហើយប្រាប់មកចុះ ។ នាគរាជពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំប្រាប់ដល់អ្នកដទៃ ដូច្នេះហើយ ក៏ឲ្យអចេលនោះទទួលបដិញ្ញា ទើបប្រាប់ថា បពិត្រលោកម្ចាស់ ពួកខ្ញុំលេបថ្មធំៗ ធ្វើឲ្យជាអ្នកមានទម្ងន់ ហើយដេក កាលគ្រុឌទាំងឡាយមក ពួកខ្ញុំឈរងើបមុខ បញ្ចេញធ្មេញ ដើម្បីនឹងចឹកគ្រុឌទាំងនោះមកហើយ ចាប់ក្បាលរបស់ពួកខ្ញុំ កាលព្យាយាមលើកពួកខ្ញុំដែលដេកដូចជាមានទម្ងន់ឡើង ទឹករមែងគ្របសង្កត់ ។ គ្រុឌទាំងនោះរមែងស្លាប់ក្នុងទឹកនោះឯង ព្រោះហេតុនេះ បានជាគ្រុឌទាំងឡាយវិនាសអស់ច្រើន ។ កាលពួកគ្រុឌចាប់ពួកខ្ញុំ មិនគួរចាប់ត្រង់ក្បាល ពួកគ្រុឌល្ងង់នោះត្រូវចាប់កន្ទុយ ធ្វើក្បាលពួកខ្ញុំ ឲ្យសំយុងចុះ ហើយរលាក់ឲ្យអាហារដែលលេបចូលទៅនោះ ចេញមកតាមមាត់ ធ្វើឲ្យស្រាលហើយ ទើបអាចនឹងនាំទៅបាន ។ នាគរាជបានប្រាប់ហេតុអាថ៌កំបាំងរបស់ខ្លួន ដល់អចេលទ្រុស្តសីល ដោយប្រការដូច្នេះ ។

*លំដាប់នោះ កាលនាគរាជចេញទៅហើយ សុបណ្ណរាជក៏មកដល់ ថ្វាយបង្គំករម្បិយ-អចេល ហើយពោលថា បពិត្រលោកម្ចាស់ ហេតុអាថ៌កំបាំងរបស់នាគរាជ លោកម្ចាស់បានសួរហើយឬ ? អចេលនោះ ពោលថា បានសួរហើយ អាវុសោ ហើយប្រាប់ហេតុនោះទាំងអស់តាមដែលនាគរាជពោលហើយ ។ សុបណ្ណរាជស្តាប់ពាក្យនោះហើយ គិតថា នាគរាជធ្វើកម្មមិនគួរ ធម្មតាវិធីដែលធ្វើឲ្យពួកញាតិវិនាស មិនគួរប្រាប់អ្នកដទៃ ថ្ងៃនេះយើងនឹងធ្វើសុបណ្ណ-វាត (ខ្យល់ដែលកើតពីគ្រុឌ) គួរដើម្បីនឹងចាប់នាគរាជនោះឯងជាដំបូង ។ ស្តេចគ្រុឌធ្វើសុបណ្ណវាត ហើយចាប់កន្ទុយបណ្ឌរនាគរាជ ធ្វើក្បាលឲ្យសំយុងចុះក្រោម ញ៉ាំងនាគរាជឲ្យខ្ជាក់ចោលអាហារ រួចហើរឡើងទៅកាន់អាកាស ។ បណ្ឌរនាគរាជ មានក្បាលសំយុងចុះក្រោម ក្នុងអាកាស ទួញសោកថា ទុក្ខរបស់យើង គឺយើងនាំមកហើយ កាលនឹងបរិទេវៈ ទើបពោលថា*

**វិកិណ្ណវាចំ អនិគុយ្ហមន្តំ, អសញ្ញតំ អបរិចក្ខិតារំ;**
**ភយំ តមន្វេតិ សយំ អពោធំ, នាគំ យថា បណ្ឌរកំ សុបណ្ណោ។**

*ភ័យខ្លួនឯង រមែងជាប់តាម នូវបុគ្គលដែលមានវាចាល្វល្វាច មានមន្តមិនលាក់ទុក ជាអ្នកមិនសង្រួម មិនចេះពិចារណា ជាអ្នកល្ងង់ ដូចជាគ្រុឌចាប់យកនាគ ឈ្មោះបណ្ឌរកៈ ។*

**យោ គុយ្ហមន្តំ បរិរក្ខណេយ្យំ, មោហា ជនេ សំសតិ ហាសមានោ;**
**តំ ភិន្នមន្តំ ភយមន្វេតិ ខិប្បំ, នាគំ យថា បណ្ឌរកំ សុបណ្ណោ។**

*ជនណាវីករាយប្រាប់មន្ត ដែលគួរលាក់ គួររក្សាទុក ព្រោះសេចក្តីវង្វេង ភ័យរមែងជាប់តាម នូវជនដែលមានមន្តបែកធ្លាយនោះដោយឆាប់ ដូចជា គ្រុឌចាប់យកនាគ ឈ្មោះបណ្ឌរកៈ ។*

ជាតុមិត្តោ គរុំ អត្ថំ, កុយ្ហំ វេទិតុមរហតិ;
សុមិត្តោ ច អសម្ពុទ្ធំ, សម្ពុទ្ធំ វា អនត្ថវា។

*មិត្តគ្រាន់តែបណ្ដោយតាម គេមិនគួរឲ្យដឹងនូវហេតុជាទម្ងន់ដែលគួរលាក់ ទាំងមិត្តល្អជាអ្នកមិនយល់ការ ឬយល់ការដែរ តែជាអ្នកមិនប្រព្រឹត្តប្រយោជន៍ (ក៏គេមិនគួរឲ្យដែរ)។*

វិស្សាសមាបជ្ជិមហំ អចេលំ, សមណោ អយំ សម្មតោ ភាវិតត្តោ;
តស្សាហមក្ខឹ វិវរឹ កុយ្ហមត្ថំ, អតីតមត្ថោ កបណំ រុទាមិ។

*អញដល់នូវសេចក្ដីទុកចិត្តអចេល អចេលនេះជាសមណៈ គេរាប់អានហើយ មានចិត្តចម្រើនហើយ អញក៏ប្រាប់បើកនូវអាថ៌កំបាំងដល់អចេលនោះ បានជាអញមានប្រយោជន៍កន្លងហួស ហើយទួញយំ កំព្រាម្នាក់ឯង ។*

តស្សាហំ បរមំ ព្រហ្មេ កុយ្ហំ, វាចំ ហិមំ ជាសក្ខឹ សំយមេតុំ;
តប្បក្ខតោ ហិ ភយមាគតំ មមំ, អតីតមត្ថោ កបណំ រុទាមិ។

*បពិត្រព្រាហ្មណ៍ដ៏ប្រសើរ ព្រោះខ្ញុំមិនអាចនឹងសង្រួមវាចាដ៏ប្រសើរកំបាំងនេះ ដល់អចេលនោះ បានជាភ័យមកដល់ខ្ញុំ អំពីចំណែកនៃអចេលនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រា ហើយទួញយំ ។*

យោ វេ នរោ សុហទំ មញ្ញមានោ, កុយ្ហមត្ថំ សំសតិ ទុក្កុលីនេ;
ទោសា ភយា អថវា រាគរត្តា, បល្លត្ថិតោ ពាលោ អសំសយំ សោ។

*ជនណាសម្គាល់នូវបុគ្គលថា មានចិត្តល្អ ប្រាប់នូវអាថ៌កំបាំង ចំពោះជនមានត្រកូលដ៏អាក្រក់ ព្រោះទោសាគតិ ភយាគតិ ឬត្រេកអរដោយអំណាចរាគៈ ជននោះជាមនុស្សល្ងង់ ឈ្មោះថា ភ្លាត់ហើយដោយឥតសង្ស័យ ។*

តិរោក្ខវាចោ អសតំ បវិដ្ឋា, យោ សង្គតីសុ មុទីរេតិ វាក្យំ;
អាសីវិសោ ទុម្មុខោត្យាហុ តំ នរំ, អារា អារា សំយមេ តាទិសម្ហា។

*ជនណាមានវាចាចេញទៅខាងក្រៅ រាប់ចូលក្នុងពួកអសប្បុរស កម្ចាយនូវពាក្យ (កំបាំងរបស់គេ) ក្នុងទីប្រជុំ អ្នកប្រាជ្ញទាំងឡាយ ហៅជននោះថា ជាអ្នកមានមាត់អាក្រក់ ដូចអាសីពិស បុគ្គលគប្បីថយចាកបុគ្គលបែបនោះ ឲ្យឆ្ងាយចេញអំពីចម្ងាយ ។*

អន្នំ បានំ កាសិកចន្ទនញ្ច, មនាបិត្ថិយោ មាលមុច្ឆាទនញ្ច;
ឱហាយ គច្ឆាមសេ សព្ពកាមេ, សុបណ្ណ បាណូបគតាវ ត្យម្ហា។

*យើងលះបង់នូវកាមទាំងពួងគឺ បាយ ទឹក សំពត់ក្នុងដែនកាសី និងខ្លឹមចន្ទន៍ ពួកស្ត្រីជាទីគាប់ចិត្ត កម្រងផ្កានិងគ្រឿងប្រស់ព្រំ បពិត្រសុបណ្ណៈ យើងសូមដល់នូវលោក (ជាទីពឹង) ស្មើដោយជីវិត ។*

*បណ្ឌរកនាគកាលមានក្បាលសំយុងចុះក្រោម ក្នុងអាកាស បានបរិទេវៈដោយគាថាទាំងឡាយ ៨ យ៉ាងនេះ ។ សុបណ្ណរាជស្តាប់សំឡេងបរិទេវៈ របស់នាគរាជនោះហើយ តិះដៀលនាគរាជថា នៃនាគរាជ អ្នកពោលប្រាប់អាថ៌កំបាំងរបស់ខ្លួនដល់អចេលក៏ ឥឡូវនេះ អ្នកបរិទេវៈ ធ្វើអ្វី ដូច្នេះហើយ ទើបពោលគាថាថា*

កោ នីធ តិណ្ហំ គរហំ ឧបេតិ, អស្មីធ លោកេ បាណភូ នាគរាជ;
សមណោ សុបណ្ណោ អថវា តុវមេវ, កិំការណា បណ្ឌរកគ្គហីតោ។

ម្នាលនាគរាជ បណ្តាជនទាំង ៣ នាក់ ក្នុងទីនេះ តើសត្វណាគឺ សមណៈ ឬគ្រុឌ ឬអ្នកឯង គួរដល់សេចក្តីតិះដៀលបាន ក្នុងលោកនេះ ម្នាលបណ្ឌរកៈ (អ្នកឯងត្រូវខ្ញុំ)ចាប់បាន ព្រោះហេតុដូចម្តេច ។

បណ្ឌរកនាគស្តាប់ពាក្យនោះហើយ ពោលគាថាដទៃទៀតថា

សមណោតិ មេ សម្មតត្តោ អហោសិ, បិយោ ច មេ មនសា ភាវិតត្តោ;
តស្សាហមក្ខឹ វិវរឹ គុយ្ហមត្ថំ, អតីតមត្តោ កបណំ រុទាមិ។

អចេលជាសមណៈ ជាបុគ្គលមានសភាពដែលខ្ញុំរាប់អានហើយ ជាទីស្រឡាញ់ដោយចិត្តរបស់ខ្ញុំ មានខ្លួនចម្រើនហើយ ខ្ញុំប្រាប់បើកអាថ៌កំបាំងដល់សមណៈនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រាហើយទួញយំ ។

បន្ទាប់មក សុបណ្ណរាជពោល ៤ គាថា ថា

ន ចត្ថិ សត្តោ អមរោ បថព្យា, បញ្ញាវិធា នត្ថិ ន និន្ទិតព្ពា;
សច្ចេន ធម្មេន ធិតិយា ទមេន, អលព្ភមព្យាហរតី នរោ ឥធ។

ធម្មតាសត្វលើផែនដី ឈ្មោះថា មិនស្លាប់ មិនមានទេ ចំណែកនៃបញ្ញា ជាធម្មជាតិដែលបុគ្គលមិនគួរតិះដៀល នរជនក្នុងលោកនេះ រមែងនាំមកនូវគុណវិសេសដែលបុគ្គលមិនគួរបាន ដោយវចីសច្ចៈ ១ ដោយសុចរិតធម៌ ១ ដោយធិតិគឺបញ្ញា ១ ដោយការទូន្មាននូវឥន្ទ្រិយ ១ ។

មាតា បិតា បរមា ពន្ធវានំ, នាស្ស តតិយោ អនុកម្បកត្ថិ;
តេសម្បិ គុយ្ហំ បរមំ ន សំសេ, មន្តស្ស ភេទំ បរិសង្កមានោ។

មាតាបិតា ជាបុគ្គលប្រសើរជាងផៅពង្សទាំងឡាយ សត្វជាគម្រប់ ៣ (ក្រៅអំពីមាតាបិតា) ឈ្មោះថាជាអ្នកអនុគ្រោះដល់បុគ្គលនោះមិនមានទេ បុគ្គលកាលវៀសនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់ការស្ងាត់កំបាំងដ៏ក្រៃលែងដល់មាតាបិតា ។

មាតា បិតា ភគិនី ភាតរោ ច, សហាយា វា យស្ស ហោន្តិ សបក្ខា;
តេសម្បិ គុយ្ហំ បរមំ ន សំសេ, មន្តស្ស ភេទំ បរិសង្កមានោ។

មាតាបិតា បងប្អូនស្រី បងប្អូនប្រុស និងសម្លាញ់ ឬញាតិទាំងពីរប៉ែក របស់បុគ្គលនោះ បុគ្គលកាលវៀសនូវការបែកធ្លាយមន្ត មិនគប្បីប្រាប់ នូវការស្ងាត់កំបាំងដ៏ក្រៃលែង ដល់មាតាបិតា ជាដើមនោះឡើយ ។

ភរិយា ចេ បុរិសំ វជ្ជា, កោមារី បិយភាណិនី;
បុត្តរូបយសូបេតា, ញាតិសង្ឃបុរក្ខតា;
តស្សាបិ គុយ្ហំ បរមំ ន សំសេ, មន្តស្ស ភេទំ បរិសង្កមានោ។

បើទុកជាភរិយា ជាស្រីក្មេង ពោលពាក្យជាទីស្រឡាញ់ មានបុត្រមានរូបល្អ មានយស ដែលពួកញាតិចោមរោម ជាស្ត្រីរៀរបុរស (ដទៃ) បុគ្គលកាលបើវៀរនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់នូវការស្ងាត់កំបាំងដ៏ក្រៃលែង ដល់ភរិយានោះទេ ។

បន្ទាប់មក ស្ដេចគ្រុឌក៏ពោលដទៃទៀតថា

ន គុយ្ហមត្ថំ វិវរេយ្យ, រក្ខេយ្យ នំ យថា និធឹ;
ន ហិ បាតុកតោ សាធុ, គុយ្ហោ អត្ថោ បជានតា។

បុគ្គលមិនគប្បីបើកនូវអាថ៌កំបាំងទេ គប្បីរក្សានូវអាថិកំបាំង ឲ្យដូចជារក្សាកំណប់ ត្បិតអាថ៌កំបាំងដែលបុគ្គលអ្នកដឹងច្បាស់ មិនប្រាប់គេ ជាការប្រពៃ ។

ឋិយា គុយ្ហំ ន សំសេយ្យ, អមិត្តស្ស ច បណ្ឌិតោ;
យោ ចាមិសេន សំហីរោ, ហទយត្ថេនោ ច យោ នរោ។

អ្នកប្រាជ្ញ មិនគប្បីនិយាយប្រាប់អាថ៌កំបាំងដល់ស្ត្រី ដល់ជនជាសត្រូវ ដល់ជនរឡិបរឡប់ដោយអាមិសៈ ដល់ជនលួចគំនិតគ្នា ។

គុយ្ហមត្ថំ អសម្ពុទ្ធំ, សម្ពោធយតិ យោ នរោ;
មន្តភេទភយា តស្ស, ទាសភូតោ តិតិក្ខតិ។

ជនណាញ៉ាំងគេឲ្យដឹងអាថ៌កំបាំងដែលគេមិនទាន់ដឹង អ្នកប្រាជ្ញតែងអត់សង្កត់ មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចមនុស្សខ្ញុំគេ ។

យាវន្តោ បុរិសស្សត្ថំ, គុយ្ហំ ជានន្តិ មន្តិនំ;
តាវន្តោ តស្ស ឧព្ពេគា, តស្មា គុយ្ហំ ន វិស្សជេ;

ជនទាំងឡាយមានចំនួនប៉ុន្មាននាក់ ដឹងនូវមន្តជាអាថ៌កំបាំងរបស់បុរស សេចក្តីតក់ស្លុតមានចំនួនប៉ុណ្ណោះ តែងកើតឡើង ដល់បុរសនោះ ព្រោះហេតុនោះអ្នកប្រាជ្ញមិនគប្បីផ្សាយនូវអាថ៌កំបាំងឡើយ ។

វិវិច្ច ភាសេយ្យ ទិវា រហស្សំ, រត្តឹ គិរំ នាតិវេលំ បមុញ្ចេ;
ឧបស្សុតិកា ហិ សុណន្តិ មន្តំ, តស្មា មន្តោ ខិប្បមុបេតិ ភេទំ។

*នៅវេលាថ្ងៃ អ្នកប្រាជ្ញគប្បីនិយាយអាថ៌កំបាំង ក្នុងទីស្ងាត់ នៅវេលារាត្រី មិនគប្បីបញ្ចេញសម្លេង ឲ្យហួសកម្រិត ព្រោះថា ពួកជនអ្នកឈ្លបស្តាប់ រមែងឮនូវមន្ត ព្រោះហេតុនោះមន្តរក៏មែងដល់នូវការបែកធ្លាយដោយឆាប់ ។*

*គាថាទាំង ៥ នេះ នឹងមានជាក់ច្បាស់ក្នុងបញ្ចបណ្ឌិតបញ្ហា ក្នុងឧមង្គជាតក ( រឿងព្រះមហោសថ) ។*

*បន្ទាប់មក សុបណ្ណរាជពោលគាថាដទៃទៀតថា*

**យថាបិ អស្ស នគរំ មហន្តំ, អទ្វារកំ អាយសំ ភទ្ទសាលំ;**
**សមន្តខាតាបរិខាឧបេតំ, ឯវម្បិ មេ តេ ឥធ គុយ្ហមន្តា។**

*ក្រុងប្រកបដោយកំពែងដែកដ៏ធំ មានទ្វារ (ចេញចូលមិនបាន) ធ្វើអំពើដែលប្រកបដោយសាលា គឺរានផ្សារដ៏ល្អ ប្រកបដោយគូដែលគេជីកជុំវិញ យ៉ាងណា បុរសមានមន្តដែលគួរលាក់ទុក ក្នុងលោកនេះ ប្រាកដដល់ខ្ញុំយ៉ាងនោះដែរ ។*

យេ គុយ្ហមន្តា អវិកិណ្ណវាចា, ទឡ្ហា សទត្ថេសុ នរា ទុជិវ្ហ;
អារា អមិត្តា ព្យវជន្តិ តេហិ, អាសីវិសា វា រិវ សត្តុសង្ឃា។

*ម្នាលអ្នកមានអណ្តាតពីរ ពួកជនណាជាអ្នកមានមន្ត គួរលាក់ទុក មានវាចាមិនល្ហល្ហាចជាអ្នកមាំមួនក្នុងប្រយោជន៍របស់ខ្លួន សត្រូវទាំងឡាយ រមែងចៀសចេញឆ្ងាយអំពីពួកជននោះ ដូចពពួកនៃសត្វ ចៀសចេញអំពីអាសីពិស ។*

*កាលស្តេចគ្រុឌពោលធម៌យ៉ាងនេះហើយ បណ្ឌរកនាគក៏ពោលថា*

**ហិត្វា ឃរំ បព្វជិតោ អចេលោ, នគ្គោ មុណ្ឌោ ចរតិ ឃាសហេតុ,**

តម្ហិ នុ ខោ រ៉ិរ៉ំ គុយ្ហមត្ថំ, អត្ថា ច ធម្មា ច អបគ្គតាម្ហា។

*អចេល ជាអ្នកបួស លះបង់ផ្ទះ អាក្រាត ត្រងោល ប្រព្រឹត្តព្រោះហេតុតែអាហារ ខ្ញុំបើកបង្ហាញនូវអាថ៌កំបាំងចំពោះអចេលនោះឯង (ព្រោះហេតុនោះ) បានជាយើងឃ្លាតចាកអត្ថនិងធម៌ ។*

កថំករោ ហោតិ សុបណ្ណរាជ, កឹសីលោ កេន វតេន វត្តំ;
សមណោ ចរំ ហិត្វា មមាយិតានិ, កថំករោ សគ្គមុបេតិ ឋានំ។

*បពិត្រសុបណ្ណរាជ បុគ្គលធ្វើដូចម្ដេច មានសីលធម៌ដូចម្ដេច ប្រព្រឹត្តវត្តដូចម្ដេច ឈ្មោះថាសមណៈ ប្រព្រឹត្តលះបង់នូវសេចក្ដីរាប់អាន (តណ្ហា) សមណៈនោះ ធ្វើដូចម្ដេច ទើបទៅកាន់ឋានសួគ៌ ។*

*សុបណ្ណរាជពោលថា*

ហិរិយា តិតិក្ខាយ ទមេនុបេតោ, អក្កោធនោ បេសុណិយំ បហាយ;
សមណោ ចរំ ហិត្វា មមាយិតានិ, ឯវំករោ សគ្គមុបេតិ ឋានំ។

*បុគ្គលប្រកបដោយហិរិ ដោយខន្តី គឺសេចក្ដីអត់ធន់ ដោយការទូន្មាន (នូវឥន្ទ្រិយ) ជាអ្នកមិនខឹង លះបង់នូវពាក្យញុះញង់ ទើបឈ្មោះថាសមណៈ ប្រព្រឹត្តលះបង់នូវសេចក្ដីរាប់អានឯសមណៈនោះ ធ្វើយ៉ាងនេះឯង ទើបចូលទៅកាន់ឋានសួគ៌បាន ។*

*មានសេចក្ដីថា នៃនាគរាជសម្លាញ់ បុគ្គលដែលប្រកបដោយហិរិនិងឱត្តប្បៈដែលជាសមុដ្ឋានខាងក្នុងនិងខាងក្រៅ មានអធិវាសខន្តី ពោលគឺសេចក្ដីអត់ធន់ មានការទូន្មានឥន្ទ្រិយ ជាអ្នកមិនក្រោធជាប្រក្រតី លះបង់បិសុណវាចា និងតណ្ហា កាលប្រព្រឹត្តដោយការ*

*បួស ទើបឈ្មោះថា សមណៈ សមណៈនោះកាលធ្វើកុសលទាំងឡាយ មានហិរិជាដើមនោះ រមែងចូលដល់ឋានសួគ៌ ។*

*បណ្ឌារកនាគបានស្តាប់ធម្មកថានេះ របស់សុបណ្ណរាជហើយ កាលសូមជីវិត ទើបពោលគាថាថា*

**មាតាវ បុត្តំ តរុណំ តនុជ្ជំ, សម្ផស្សតា សព្ពគត្តំ ផរេតិ;**
**ឯវម្បិ មេ ត្វំ បាតុរហុ ទិជិន្ទ, មាតាវ បុត្តំ អនុកម្បមានោ។**

*មាតាឃើញកូនខ្ចី ដែលកើតអំពីខ្លួន ហើយបបោសអង្អែលសព្វសព៌ាង្គកាយ យ៉ាងណាមិញ បពិត្រលោកជាធំជាងបក្សី លោកជាអ្នកអនុគ្រោះ ប្រាកដដល់ខ្ញុំ ដូចជាមាតា (អនុគ្រោះ) នូវបុត្រ យ៉ាងនោះ ។*

*លំដាប់នោះ សុបណ្ណរាជកាលឲ្យជីវិតដល់នាគនោះ ទើបពោលគាថាដទៃថា*

**ហន្ទជ្ជ ត្វំ មុញ្ច វធា ទុជិវ្ហ, តយោ ហិ បុត្តា ន ហិ អញ្ញោ អត្ថិ;**
**អន្តេវាសី ទិន្នកោ អត្រជោ ច, រជ្ជស្សុ បុត្តញ្ញតរោ មេ អហោសិ។**

*នែអ្នកមានអណ្តាតពីរ អ្នកចូររួចអំពីការសម្លាប់ ក្នុងថ្ងៃនេះចុះ ព្រោះថាបុត្តមាន ៣ គឺ សិស្ស ១ កូនគេឲ្យ ១ កូនកើតអំពីខ្លួន១ បុត្តក្រៅពីនេះមិនមានឡើយ អ្នកចូរត្រេកអរចុះ អ្នកទុកជាបុត្តណាមួយ របស់ខ្ញុំហើយ ។*

*ស្តេចគ្រុឌពោលយ៉ាងនេះហើយ ក៏ចុះចាកអាកាស ដាក់នាគរាជលើផែនដី ។*

*ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថា ២ ថា*

**ឥច្ចេវ វាក្យំ វិសជ្ជី សុបណ្ណោ, ភុម្យំ បតិដ្ឋាយ ទិជោ ទុជិវ្ហំ;**

មុត្តជ្ជ ត្វំ សព្ពភយាតិវត្តោ, ថលូទកេ ហោហិ មយាភិគុត្តោ។

*ស្ដេចគ្រុឌមានកំណើតពីរ ( លុះពោកពាក្យ) យ៉ាងនេះហើយ ក៏បិតនៅលើផែនដី លែងសត្វមានអណ្ដាតពីរ ដោយពាក្យថា អ្នករួចក្នុងថ្ងៃនេះ កន្លងនូវភ័យទាំងពួងហើយ អ្នកត្រូវខ្ញុំគ្រប់គ្រង ក្នុងទីគោកនិងទឹកហើយ ។*

អាតង្កិនំ យថា កុសលោ ភិសក្កោ, បិបាសិតានំ រហទោវ សីតោ;
វេស្មំ យថា ហិមសីតដ្ដិតានំ, ឯវម្បិ តេ សរណមហំ ភវាមិ។

*ខ្ញុំជាទីពឹងរបស់អ្នក ដូចជាពេទ្យដ៏ឈ្លាស (ជាទីពឹង) របស់ពួកអ្នកមានជំងឺ ឬដូចជាអន្លង់ទឹកត្រជាក់ (ជាប្រយោជន៍) របស់ពួកអ្នកស្រេកទឹក ឬក៏ដូចផ្ទះ (ជាទីត្រូវការ) របស់ពួកបុគ្គលដែលលំបាក ដោយសន្សើមត្រជាក់ ។*

*ស្ដេចគ្រុឌដោះលែងនាគថា អ្នកចូរទៅចុះ ។ នាគរាជនោះ ចូលកាន់ពិភពនាគ ។ សូម្បីស្ដេចគ្រុឌទៅកាន់សុបណ្ណភព ហើយគិតថា បណ្ណរកនាគ យើងបានឲ្យធ្វើការស្បថ ឲ្យយើងជឿហើយ ឲ្យដោះលែង យើងនឹងដឹងចិត្តរបស់នាគនោះ ដែលគិតចំពោះយើងដូចម្ដេចដូច្នេះហើយ ក៏ទៅកាន់ពិភពនាគ និងធ្វើសុបណ្ណវាត ។ នាគឃើញគ្រុឌនោះហើយ សម្គាល់ថា សុបណ្ណរាជនឹងមកចាប់យើង ដូច្នេះទើបធ្វើអត្តភាពឲ្យមានប្រមាណ ១០០០ ព្យាម (បួនពាន់ហត្ថ) លេបថ្ម និងខ្សាច់ ធ្វើឲ្យមានទម្ងន់នៅកន្ទុយខាងក្រោម ដេកបើកពពារលើកំពូលភ្នែន ធ្វើហាក់ដូចជាប្រាថ្នានឹងចឹកស្ដេចគ្រុឌ ។ ស្ដេចគ្រុឌឃើញនាគនោះ ទើបពោលគាថាថា*

សន្ធឹ កត្វា អមិត្តេន, អណ្ឌជេន ជលាពុជ;
វិវរិយ ទាឋំ សេសិ, កុតោ តំ ភយមាគតំ។

ម្នាលអ្នកជាជលាពុជៈ អ្នកធ្វើសេចក្ដីស្និទ្ធស្នាល ជាមួយនឹងអណ្ឌជៈជាសត្រូវ ហើយនៅបើកបង្ហាញចង្កូម (ធ្វើអ្វីទៀត) ភ័យនឹងមកដល់អ្នក អំពីទីណា ។

នាគរាជស្ដាប់ពាក្យនោះហើយ ទើបពោល ៣ គាថា ថា

សង្កេថេវ អមិត្តស្មឹ, មិត្តស្មិម្បិ ន វិស្សសេ;
អភយា ភយមុប្បន្នំ, អបិ មូលានិ កន្តតិ។

បុគ្គលត្រូវតែរង្កៀសក្នុងបុគ្គលជាសត្រូវ មិនត្រូវទុកចិត្តបុគ្គលសូម្បីជាមិត្ត (ព្រោះ) ភ័យរមែងកើតឡើងអំពីបុគ្គលដែលមិនគួរភ័យ រមែងកាត់សូម្បីនូវឫសគល់ (ជីវិត) ។

កថំ នុ វិស្សសេ ត្យម្ហិ, យេនាសិ កលហោ កតោ;
និច្ចយត្តេន ឋាតព្វំ, សោ ទិសព្ភិ ន រជ្ជតិ។

បុគ្គលធ្វើនូវជម្លោះនឹងជនណា គប្បីទុកចិត្តជននោះដូចម្ដេចកើត បុគ្គលគប្បីឋិតនៅដោយប្រុងប្រយ័ត្នជានិច្ច បុគ្គលនោះ រមែងមិនត្រេកអរនឹងសត្រូវ ។

វិស្សាសយេ ន ច តំ វិស្សយេយ្យ, អសង្កិតោ សង្កិតោ ច ភវេយ្យ;
តថា តថា វិញ្ញូ បរក្កមេយ្យ, យថា យថា ភាវំ បរោ ន ជញ្ញា។

បុគ្គលគប្បីធ្វើឲ្យគេទុកចិត្ត ប៉ុន្តែមិនត្រូវទុកចិត្តគេ បុគ្គលដែលគេមិនរង្កៀសហើយ ប៉ុន្តែគប្បីរង្កៀសនឹងគេ បុគ្គលដទៃមិនដឹងនូវភាព (របស់ខ្លួន) យ៉ាងណាៗ វិញ្ញូបុរស គប្បីប្រឹងប្រែង ដោយប្រការយ៉ាងនោះៗ ។

គ្រាសត្វទាំងពីរនោះសន្ទនាគ្នាយ៉ាងនេះហើយ កាលមានសេចក្ដីរីករាយ ជាមួយគ្នា ទើបសត្វទាំងពីរ ទៅកាន់អាស្រមរបស់អចេលក៏ ។

*ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ថា*

**តេ ទេវវណ្ណា សុខុមាលរូបា, ឧភោ សមា សុជយា បុញ្ញខន្ធា;**
**ឧបាគមុំ ការម្បិយំ អចេលំ, មិស្សីភូតា អស្សវាហាវ ជាគា។**

*បុរិសនាគទាំងពីរនោះ មានវណ្ណៈដូចជាទេវតា មានសភាពជាសុខុមាលជាតិស្មើគ្នា មានវ័យដ៏ល្អ មានគំនរនៃបុណ្យ កៀកដៃគ្នា ដូចជាសេះគេទឹម បានចូលទៅកាន់សំណាក់នៃអចេល ឯកំពង់ករម្បិយៈ ។*

*គ្រាទៅដល់ហើយ សុបណ្ណរាជគិតថា នាគរាជនេះ នឹងមិនឲ្យជីវិតដល់អចេលក៏ យើងនឹងថ្វាយបង្គំបុគ្គលទ្រុស្តសីលនោះ ។ ស្តេចគ្រុឌទើបឈរនៅខាងក្រៅ ហើយបញ្ជូននាគរាជប៉ុណ្ណោះទៅកាន់សម្នាក់អចេលក៏នោះ ។*

*ព្រះសាស្តាសំដៅដល់ហេតុនោះ ទើបត្រាស់ព្រះគាថាដទៃថា*

**តតោ ហវេ បណ្ឌរកោ អចេលំ, សយមេវុបាគម្ម ឥទំ អវោច;**
**មុត្តជ្ជហំ សព្ពភយាតិវត្តោ, ន ហិ នូន តុយ្ហំ មនសោ បិយម្ហា។**

*លំដាប់នោះឯង បណ្ឌរកនាគរាជ បានចូលទៅកាន់សំណាក់នៃអចេលដោយខ្លួនឯង ហើយពោលពាក្យនេះថា ខ្ញុំរួច (អំពីការសម្លាប់) កន្លងនូវភ័យទាំងពួង ក្នុងថ្ងៃនេះហើយ យើងមិនជាទីស្រឡាញ់របស់លោកដោយចិត្តពិតប្រាដកទេ ។*

*លំដាប់នោះ អចេលក៏ពោលគាថាដទៃថា*

**បិយោ ហិ មេ អាសិ សុបណ្ណរាជា, អសំសយំ បណ្ឌរកេន សច្ចំ;**
**សោ រាគរត្តោវ អកាសិមេតំ, បាបកម្មំ សម្បជានោ ន មោហា។**

*សុបណ្ណរាជ ជាទីស្រឡាញ់របស់ខ្ញុំ ជាងបណ្ឌរកនាគរាជមែន ឥតសង្ស័យ (នេះ) ជាពាក្យពិត ខ្ញុំនោះជាអ្នកត្រេកអរដោយរាគៈ ជាអ្នកដឹងច្បាស់ បានធ្វើនូវអំពើអាក្រក់នុ៎ះ មិនមែនព្រោះមោហៈទេ ។*

*នាគរាជស្តាប់ពាក្យនោះហើយ ពោល ២ គាថាថា*

ន មេ បិយំ អប្បិយំ វាបិ ហោតិ, សម្បស្សតោ លោកមិមំ បរញ្ច;
សុសញ្ញតានញ្ហិ វិយញ្ជនេន, អសញ្ញតោ លោកមិមំ ចរាសិ។

*បព្វជិត កាលឃើញច្បាស់នូវលោកនេះ និងលោកខាងមុខ រមែងមិនមានគំនិតថា វត្ថុជាទីស្រឡាញ់ ឬជាទីមិនស្រឡាញ់ របស់អញដូច្នេះទេ អ្នកជាបុគ្គលមិនសង្រួមប្រព្រឹត្ត ក្នុងលោកនេះ ដោយភេទ របស់បុគ្គលអ្នកសង្រួមល្អ ។*

អរិយាវកាសោសិ អនរិយោវាសិ, អសញ្ញតោ សញ្ញតសន្និកាសោ;
កណ្ហាភិជាតិកោសិ អនរិយរូបោ, ពាបំ ពហុំ ទុច្ចរិតំ អចារិ។

*អ្នកឯងបន្ទំជាអរិយៈតែមិនមែនជាអរិយៈទេ អ្នកមិនសង្រួម តែមានភាពហាក់ដូចជាអ្នកសង្រួម មានជាតិខ្មៅ មានសភាពមិនប្រសើរ បានប្រព្រឹត្តនូវអំពើដ៏លាមកជាទុច្ចរិតច្រើនយ៉ាង ។*

*កាលនាគរាជតិះដៀលអចេលក៍នោះយ៉ាងនេះហើយ ឥឡូវនេះកាលនឹងផ្តាសា ទើបពោលគាថានេះថា*

អទុដ្ឋស្ស តុវំ ទុព្ភិ, ទុព្ភី ច បិសុណោ ចសិ;
ឯតេន សច្ចវជ្ជេន, មុទ្ធា តេ ផលតុ សត្តធា។

***ម្នាលអ្នកប្រទូស្ត អ្នកជាបុគ្គលប្រទូស្តមិត្ត ដែលមិនបានប្រទូស្តវិញផង ជាអ្នកញុះញង់ផង ដោយពាក្យសច្ចៈនេះ សូមឲ្យក្បាលរបស់អ្នកឯង បែកជា ៧ ភាគ ។***

*គាថានេះមានសេចក្តីថា នៃអ្នកប្រទូស្ត អ្នកទ្រុស្តមិត្តដែលមិនប្រទូស្តផង ជាអ្នកនិយាយចាក់ដោតផង ដោយពាក្យសច្ចៈនេះ សូមឲ្យក្បាលរបស់អ្នកបែកជា ៧ ចម្រៀក ។*

*កាលនាគរាជដាក់បណ្តាសាយ៉ាងនេះហើយ ក្បាលអចេលកក៏បែកជា ៧ ភាគ ។ ផែនដីត្រង់កន្លែងដែលអចេលកអង្គុយនោះ បានរហែក ធ្វើជាចន្លោះ ។ អចេលកនោះចូលទៅកាន់ផែនដី ហើយកើតក្នុងអវីចិនរក ។ ចំណែកនាគរាជ និងសុបណ្ណរាជ ក៏បានទៅកាន់ភពរបស់ខ្លួនវិញ ។*

*ព្រះសាស្តា កាលប្រកាសភាពដែលអចេលកនោះចូលទៅកាន់ផែនដី ទើបត្រាស់ព្រះឱសានគាថា ថា*

**តស្មា ហិ មិត្តានំ ន ទុព្ភិតព្វំ, មិត្តទុព្ភា បាបិយោ នត្ថិ អញ្ញោ;**
**អាសិត្តសត្តោ និហតោ បថព្យា, ឥន្ទស្ស វាក្យេន ហិ សំវរោ ហតោ។**

***ព្រោះហេតុនោះ បុគ្គលមិនត្រូវប្រទូស្តមិត្តទាំងឡាយឡើយ ព្រោះថា សភាវៈដទៃលាមកជាងការទ្រុស្តមិត្ត មិនមានទេ អចេលអ្នកសង្រួម ត្រូវសត្វអាសីពិសប្រទេចផ្តាសា ក៏ខ្ទាត់ចេញអំពីផែនដី វិនាសតាមពាក្យរបស់នាគរាជដ៏ប្រសើរ ។***

*ពាក្យថា* ***អចេលជាអ្នកសង្រួម****នេះ បានសេចក្តីថា អាជីវកនោះ បានប្រាកដថា ជាអ្នកសង្រួម ដោយពាក្យប្តេជ្ញាថា យើងឋិតនៅក្នុងសេចក្តីសង្រួម ។*

*ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ទេវទត្តធ្វើមុសាវាទហើយ ក៏ត្រូវផែនដីស្រូបដូចគ្នាដែរ ដូច្នេះហើយ ព្រះអង្គប្រជុំជាតកថា*

**តទា អចេលកោ ទេវទត្តោ អហោសិ** *អចេលក៏ក្នុងកាលនោះ បានមកជាទេវទត្ត*

**ជាគរាជា សារិបុត្តោ** *នាគរាជបានមកជាសារីបុត្រ*

**សុបណ្ណរាជា បន អហមេវ អហោសិំ** *ចំណែកសុបណ្ណរាជ គឺ តថាគតនេះឯង ។*

*ចប់ បណ្ឌរនាគរាជជាតក ។*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តឹសនិបាត បិដកលេខ ៦០ ទំព័រ ២០០)*

*ថ្ងៃច័ន្ទ ១៥ រោច ខែវិសាខ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ១៤ ខែ ឧសភា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*